ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៤ ភ.សរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈប្រតិភូកម្ពុជា សំរាប់ធ្វើការចរចាជាមួយគណៈប្រតិភូរបស់អង្គការយូណេស្កូ លើការចុះឈ្មោះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

*************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់តំណាងអង្គការយូណេស្កូ (UNESCO) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- តាមសភាពការណ៍ចាំបាច់

## សំរេច

**ប្រការ១:** បង្កើតគណៈប្រតិភូកម្ពុជាសំរាប់ធ្វើការចរចាជាមួយគណៈប្រតិភូរបស់អង្គការយូណេស្កូលើការចុះឈ្មោះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម នី យ៉ាន | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- | ឯកឧត្តម វ៉ា គឹមហុង | ប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជាថៃ | អនុប្រធាន |
| ៤- | ឯកឧត្តម ទី សាឃី | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- | ឯកឧត្តម ជួច ភឿន | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |

| | | |
|---|---|---|
| ៦- ឯកឧត្តម **រស់ បូរ៉ាត់** | អគ្គនាយករងអាជ្ញាធរអប្សរានិងជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិអង្គការ យូណេស្កូ | សមាជិក |
| ៧- លោកជំទាវ **តាន់ ធានី** | អគ្គលេខាធិការគណៈកម្មការជាតិកម្ពុជាសំរាប់យូណេស្កូ | សមាជិកា |
| ៨- លោក **មុខ ម៉ិនឃួន** | ប្រធាននាយកដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

**ប្រការ២:** គណៈប្រតិភូកម្ពុជាមានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ ប្រមូលលិខិតបទដ្ឋានគតិយុត្តិគ្រប់ជំនាន់ ផែនទីនានា និងឯកសារពាក់ព័ន្ធជុំវិញប្រាសាទព្រះវិហារ ដើម្បីធ្វើជាទឡ្ហីករណ៍ក្នុងការចរចាជាមួយអង្គការយូណេស្កូ (UNESCO) ។
- ប្រជុំដើម្បីប្រមូលផ្តុំនូវយោបល់សំខាន់ៗជាគន្លឹះ សំរាប់បំរើការក្នុងការងារចរចាជាក់ស្តែងជាមួយអង្គការយូណេស្កូ(UNESCO) ។
- បូកសរុបខ្លឹមសារនៃការត្រៀមរៀបចំឯកសារ និងខ្លឹមសារចរចាដើម្បីរាយការណ៍សុំយោបល់ណែនាំដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល ។
- ក្រោយពេលចរចាចប់ ត្រូវរាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣:** សមាជិកគណៈប្រតិភូកម្ពុជាត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈប្រតិភូ ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ, នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មករា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ